**ក្រុង Lowell • ក្រសួងសុខាភិបាល**

**អង្គភាពសុខាភិបាលសាលា**

**107 Merrimack Street • Lowell, MA 01852**
**P: 978.674-4305 • F: 978.446-7100**
**www.LowellMA.gov**

# ថ្មី! លក្ខខណ្ឌតម្រូវឲ្យមានការចាក់ថ្នាំបង្ការជំងឺផ្តាសាយសម្រាប់ការចូលរៀននៅសាលា

ដោយចាប់ផ្តើមពីឆ្នាំសិក្សា 2020-2021 តទៅ ការចាក់ថ្នាំបង្ការជំងឺផ្តាសាយនឹងជា**លក្ខខណ្ឌតម្រូវសម្រាប់សិស្សគ្រប់រូប។** នៅអំឡុង ពេលនៃជំងឺរាតត្បាត COVID-19 ការចាក់ថ្នាំបង្ការជំងឺផ្តាសាយនឹងជាការចាំបាច់ជាពិសេសដើម្បីកាត់បន្ថយផលប៉ះពាល់ទូទៅ នៃជំងឺផ្លូវដង្ហើមទៅលើប្រជាជន ការពារប្រជាជនដែលងាយរងគ្រោះពីជំងឺធ្ងន់ធ្ងរ និងកាត់បន្ថយបន្ទុកទូទៅលើប្រព័ន្ធសុខាភិបាល។

**តើសិស្សប្រភេទណាដែលចាំបាច់ត្រូវចាក់ថ្នាំបង្ការជំងឺផ្តាសាយ?**
សិស្សចាប់ពីកុមារដ្ឋានរហូតដល់ថ្នាក់ទី 12 នឹងចាំបាច់ត្រូវទទួលថ្នាំបង្ការជំងឺផ្តាសាយសម្រាប់រដូវជំងឺផ្តាសាយបច្ចុប្បន្ន សម្រាប់ការចូលរៀននៅសាលា។

**តើនៅពេលណាដែលសិស្សចាំបាច់ត្រូវចាក់ថ្នាំបង្ការជំងឺផ្តាសាយ?**
សិស្សត្រូវចាក់ថ្នាំបង្ការជំងឺផ្តាសាយសម្រាប់រដូវជំងឺផ្តាសាយបច្ចុប្បន្នឲ្យបានត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 ។

**តើសិស្សដែលមិនមានឯកសារបញ្ជាក់ថាបានទទួលថ្នាំបង្ការជំងឺផ្តាសាយតាមរដូវគួរតែមិនត្រូវអនុញ្ញាតឲ្យចូលសាលារៀននៅថ្ងៃទី 1 ខែ មករា នេះឬទេ?**
សិស្សដែលមិនទាន់បានការចាក់ថ្នាំបង្ការជំងឺផ្តាសាយបានត្រឹមថ្ងៃទី 1 ខែ មករា ឆ្នាំ 2021 នឹងមិនត្រូវបានអនុញ្ញាតឲ្យចូលសាលារៀននោះទេ។

**រួចចុះសិស្សដែលចុះឈ្មោះក្រោយថ្ងៃទី 31 ខែ ធ្នូ វិញ យ៉ាងម៉េចដែរ?**
សិស្សដែលទើបចុះឈ្មោះចូលរៀនថ្មីនៅចន្លោះថ្ងៃទី 1 ខែ មករា និង ថ្ងៃទី 31 ខែ មិនា ត្រូវតែមានឯកសាបញ្ជាក់ពីការទទួលបានថ្នាំបង្ការជំងឺផ្តាសាយសម្រាប់រដូវជំងឺផ្តាសាយបច្ចុប្បន្ននេះ (រួមជាមួយនឹងការចាក់ថ្នាំបង្ការដែលបានតម្រូវផ្សេងទៀតទាំងអស់ផងដែរ) នៅពេលពួកគេចាប់ផ្តើមចូលរៀននៅសាលា។

**តើការចាក់ថ្នាំបង្ការជំងឺផ្តាសាយនឹងក្លាយជាលក្ខខណ្ឌតម្រូវជារៀងរាល់ឆ្នាំឬគ្រាន់តែសម្រាប់ឆ្នាំសិក្សា 2020-2021 នេះប៉ុណ្ណោះ?**
ការចាក់ថ្នាំបង្ការជំងឺផ្តាសាយឥឡូវនេះគឺជាលក្ខខណ្ឌតម្រូវសម្រាប់ការចូលរៀននៅសាលា ហើយនឹងក្លាយជាលក្ខខណ្ឌតម្រូវចាប់ពីថ្ងៃទី 31 ខែ ធ្នូ នេះតទៅសម្រាប់សិស្សគ្រប់រូបតាំងពីថ្នាក់កុមារដ្ឋានរហូតដល់ថ្នាក់ទី 12 ជារៀងរាល់ឆ្នាំ សិក្សា។

**ប្រសិនបើសាលានឹងត្រូវផ្តល់ការបង្ហាត់បង្រៀនពីចម្ងាយ តើសិស្សនៅតែចាំបាច់ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវឲ្យចាក់ថ្នាំបង្ការទៀតឬទេ?** លក្ខខណ្ឌតម្រូវឲ្យចាក់ថ្នាំបង្ការដើម្បីចូលរៀននៅសាលា ដែលរួមមានទាំងលក្ខខណ្ឌតម្រូវឲ្យចាក់ថ្នាំបង្ការជំងឺផ្តាសាយតាមរដូវផងដែរនោះ អនុវត្តចំពោះគ្រប់សិស្សក្នុងរដ្ឋ Massachusetts ទាំងអស់ដែលបានចុះឈ្មោះចូលរៀនពីថ្នាក់កុមារដ្ឋានរហូតដល់ថ្នាក់ទី 12 ដោយមិនគិតដល់ថាតើសង្កាត់នេះកំពុងផ្តល់ការបង្ហាត់បង្រៀនដោយផ្ទាល់ ឬក៏កំពុងប្រើមធ្យោបាយរៀនស្ទូត្រពីចម្ងាយ ឬដោយផ្ទាល់ផងនិងពីចម្ងាយផង ឬយ៉ាងណានោះទេ។